# លិខិតរបស់គ្រីស្តទូតប៉ូល
# ផ្ញើជូនគ្រីស្តបរិស័ទស្រុកកាឡាទី

## ពាក្យលំនាំ

ស្រុកកាឡាទី ៖ ស្រុកកាឡាទីនៅប៉ែកខាងជើងក្រុងអន់ទីយ៉ូក នៅស្រុកពីស៊ីឌីគីនៅកណ្តាលប្រទេសទួរគីសព្វថ្ងៃ។

ព្រះសហគមន៍ ៖

គ្រីស្តទូតប៉ូលប្រកាសដំណឹងល្អនៅស្រុកកាឡាទីពីរដង គឺនៅពេលបំពេញបេសកកម្មទី១ម្តង (កក១៦,៦) និងនៅពេលបំពេញបេសកកម្មទី២ ម្តងទៀត (កក ១៨,២៣)។ លើកទីមួយ «ព្រះវិញ្ញាណឃាត់ » លោកមិនឲ្យទៅមុខគឺ លោកមានជំងឺម្យ៉ាង (កាឡ ៤,១៣-១៤)។ ប្រជាជនស្រុកនោះពុំដែលស្គាល់ធម្មវិន័យរបស់លោកម៉ូសេទេ តែគេធ្លាប់ថ្វាយបង្គំអារក្ខអ្នកតា ធាតុអរូបី ជា«ឥទ្ធិពលឥតបានការ» វិញ (កាឡ ៤,៣.៩)។ ប៉ុន្តែ អ្នកខ្លះទទួលដំណឹងល្អ ប្រែចិត្តគំនិតនិងថ្វាយខ្លួនចំពោះព្រះគ្រីស្តជាអម្ចាស់ដោយចិត្តស្មោះ។

លិខិតគ្រីស្តទូតប៉ូល

ក្រោយពីគ្រីស្តទូតប៉ូលចាកចេញពីពួកគេទៅ មានជនជាតិយូដាខ្លះ មកញុះញង់បញ្ចុះបញ្ចូលពួកគេ ឲ្យគោរពតាមធម្មវិន័យលោកម៉ូសេ គឺឲ្យគេទទួលពិធីកាត់ស្បែកជាដើម (៣,២-៣ ; ៥, ២; ៦,១២)។ ពួកគេធ្លាប់និយាយដូចមានចងក្នុងគម្ពីរកិច្ចការថា៖ «ប្រសិនបើបងប្អូនមិនទទួលពិធីកាត់ស្បែកទេ បងប្អូនមិនអាចទទួលការសង្គ្រោះបានទេ» (កក ១៥,១)។ តាមពិត ជនជាតិយូដាទាំងនោះទោះបីគេទទួលពិធីកាត់ស្បែកហើយក៏ដោយ ក៏គេគោរពធម្មវិន័យមិនសូវល្អដែរ។

គ្រីស្តទូតប៉ូលទទួលដំណឹងនេះ នៅពេលលោកស្នាក់នៅក្រុងអេភេសូ នា គ.ស.៥៦-៥៧។ លោកសរសេរលិខិតនេះ ដោយយល់ឃើញថា គ្រីស្តបរិស័ទវង្វេងជំនឿយ៉ាងខ្លាំង គឺគេ « ឃ្លាតពីសេចក្តីពិតដែលនៅក្នុងព្រះគ្រីស្ត »។ លោកសរសេរពាក្យធ្ងន់ៗថា គេជាជន « ល្ងីល្ងើ » (៣,១)។ខាងដើមលិខិត លោកមិនអរព្រះគុណព្រះជាម្ចាស់តាមទម្លាប់លោកទេ។ លោករំឭកគ្រីស្តបរិស័ទអំពីគោលសំខាន់នៃដំណឹងល្អអំពីព្រះគ្រីស្ត គឺមនុស្សមិនទទួលការសង្គ្រោះដោយពឹងផ្អែកលើកុសលផលបុណ្យរបស់ខ្លួន ដែលប្រព្រឹត្តតាមធម្មវិន័យរបស់លោកម៉ូសេ ឬដោយខ្លួនធ្វើពិធីបុណ្យផ្សេងៗនោះទេ គឺមនុស្សទទួលការសង្គ្រោះ ដោយខ្លួនផ្ញើជីវិតទាំងស្រុងលើព្រះគ្រីស្ត ដែលរំដោះគេឲ្យរួចពីនឹមនៃធម្មវិន័យវិញ។ ការសង្គ្រោះមិនមកពីការខិតខំប្រឹងប្រែងរបស់ខ្លួនទេ គឺមកពីមនុស្សទទួលព្រះអំណោយទានរបស់ព្រះជាម្ចាស់ ដោយផ្ញើជីវិតលើព្រះគ្រីស្ត។ ធម្មវិន័យរបស់លោកម៉ូសេ គ្រាន់តែអប់រំជនជាតិអ៊ីស្រាអែលកាលពីដើម ឲ្យប្រព្រឹត្តអំពើល្អប៉ុណ្ណោះ តែពុំអាចសង្គ្រោះមនុស្សបានឡើយ (២,២០)។ ដំណឹងល្អរបស់ព្រះគ្រីស្តផ្តល់សេរីភាពដ៏ពេញលេញ ដល់អ្នកជឿ តែអ្នកផ្ញើជីវិត

លើព្រះគ្រីស្ដក៏ត្រូវយកចិត្តទុកដាក់ប្រព្រឹត្តអំពើល្អតាមព្រះវិញ្ញាណណែនាំដែរដើម្បីស្របតាមលក្ខណៈ
ថ្មីដ៏ប្រសើររបស់ខ្លួនជាបុត្រធីតារបស់ព្រះជាម្ចាស់។

# លិខិតរបស់គ្រីស្ដទូតប៉ូល ផ្ញើជូនគ្រីស្ដបរិស័ទស្រុកកាឡាទី

## ពាក្យជម្រាបសួរ

១ខ្ញុំប៉ូលជាគ្រីស្ដទូត* មិនមែនតែងតាំងឡើង
១ដោយមនុស្សលោក ឬដោយជនណាម្នាក់នោះ
ឡើយ គឺតែងតាំងឡើងដោយព្រះយេស៊ូគ្រីស្ដ និង
ព្រះជាម្ចាស់ ជាព្រះបិតាដែលប្រោសព្រះអង្គឲ្យតើន
ឡើងពីចំណោមមនុស្សស្លាប់។ ២ខ្ញុំនិងបងប្អូនទាំង
អស់ដែលនៅជាមួយខ្ញុំ សូមជម្រាបមកព្រះសហគម
ន៍ទាំងឡាយ នៅស្រុកកាឡាទី។ ៣សូមព្រះជាម្ចាស់
ជាព្រះបិតានៃយើង និងព្រះអម្ចាស់យេស៊ូគ្រីស្ដ
ប្រោសប្រណី ហើយប្រទានសេចក្ដីសុខដល់បងប្អូ
ន។ ៤ព្រះអម្ចាស់យេស៊ូបានបូជាព្រះជន្មរបស់ព្រះ
អង្គផ្ទាល់ព្រោះតែបាបរបស់យើង ព្រះអង្គបានរំដោះ
យើង ឲ្យរួចផុតពីលោកីយ៍ដ៏អាក្រក់នេះស្របតាម
ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ជាព្រះបិតារបស់យើ
ង។ ៥សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ អស់
កល្បជាអង្វែងតរៀងទៅ! អាម៉ែន!

## ដំណឹងល្អមានតែមួយគត់

៦ខ្ញុំឆ្ងល់ណាស់ ដោយឃើញបងប្អូនឆាប់ងាក
ចេញពីព្រះជាម្ចាស់ដែលបានត្រាស់ហៅបងប្អូន តាម
ព្រះហឫទ័យប្រោសប្រណីរបស់ព្រះគ្រីស្ដ ហើយបង
ប្អូនបែរទៅរកដំណឹងល្អមួយផ្សេងទៀត ៧តាមពិត
គ្មានដំណឹងល្អណាមួយផ្សេងទៀតឡើយ គឺមានតែ
អ្នកខ្លះបានធ្វើឲ្យកើតវឹកវរ និងចង់បំភ្លៃដំណឹងល្អ
របស់ព្រះគ្រីស្ដប៉ុណ្ណោះ។ ៨ប្រសិនបើមាននរណា
ម្នាក់ ទោះបីយើងក្ដី ឬទេវទូត*ណាមួយពីស្ថានបរម
សុខ*ក្ដី នាំដំណឹងល្អណាផ្សេងមកប្រាប់បងប្អូន
ខុសប្លែកពីដំណឹងល្អ ដែលយើងបាននាំមកជូនបង
ប្អូន សូមឲ្យអ្នកនោះត្រូវបណ្ដាសាទៅចុះ! ដូចយើង
បានជម្រាបមកស្រាប់ហើយ តែខ្ញុំក៏សូមជម្រាបម្ដង
ទៀតថា ប្រសិនបើនរណាម្នាក់នាំដំណឹងល្អផ្សេង
មកជូនបងប្អូន ខុសប្លែកពីដំណឹងល្អដែលបងប្អូន
ធ្លាប់ទទួលសូមឲ្យអ្នកនោះត្រូវបណ្ដាសាចុះ!

១០ឥឡូវនេះ តើខ្ញុំចង់ផ្គាប់ចិត្តមនុស្ស ឬធ្វើឲ្យ
គាប់ព្រះហឫទ័យព្រះជាម្ចាស់? តើខ្ញុំស្វែងរកឲ្យ
មនុស្សពេញចិត្តឬ? ប្រសិនបើខ្ញុំនៅតែចង់ឲ្យមនុស្ស
ពេញចិត្តនោះមានន័យថា ខ្ញុំលែងជាអ្នកបម្រើរបស់
ព្រះគ្រីស្ដទៀតហើយ!

១១ខ្ញុំសូមជម្រាបបងប្អូនថា ដំណឹងល្អ*ដែលខ្ញុំ
បាននាំមកជូនបងប្អូន មិនមែនមានប្រភពចេញមកពី
មនុស្សលោកទេ ១២រីឯខ្ញុំផ្ទាល់ ខ្ញុំក៏ពុំបានទទួលឬ
រៀនពីមនុស្សណាម្នាក់ដែរ គឺព្រះយេស៊ូគ្រីស្ដ*ឯ
ណោះដែលបានសម្ដែងឲ្យខ្ញុំស្គាល់។

១៣បងប្អូនបានឮគេនិយាយអំពី កិរិយាមារយាទ
របស់ខ្ញុំកាលពីដើមស្រាប់ហើយ គឺពេលខ្ញុំកាន់

សាសនាយូដានៅឡើយ ខ្ញុំបានបៀតបៀនព្រះសហគមន៍របស់ព្រះជាម្ចាស់ យ៉ាងកាចសាហាវបំផុត ហើយខ្ញុំក៏ចង់កម្ទេចព្រះសហគមន៍នេះ ទៀតផង។ [14]ខ្ញុំកាន់សាសនាយូដាយ៉ាងល្អប្រសើរ ជាងអស់អ្នកដែលមានអាយុស្រករៗខ្ញុំ និងជាជនរួមជាតិរបស់ខ្ញុំទៅទៀត ដ្បិតខ្ញុំមានចិត្តខ្នះខ្នែងកាន់តាមប្រពៃណីបុព្វបុរសរបស់ខ្ញុំហួសប្រមាណ។

[15]ក៏ប៉ុន្តែ ព្រះជាម្ចាស់បានជ្រើសរើសខ្ញុំទុកដោយឡែកតាំងពីក្នុងផ្ទៃម្ដាយមកម៉្លេះ ហើយព្រះអង្គបានត្រាស់ហៅខ្ញុំ ដោយព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ។ [16]នៅពេលព្រះអង្គសព្វព្រះហឫទ័យសម្ដែងឲ្យខ្ញុំស្គាល់ព្រះបុត្រារបស់ព្រះអង្គ ដើម្បីឲ្យខ្ញុំនាំដំណឹងល្អអំពីព្រះបុត្រា ទៅជូនសាសន៍ដទៃខ្ញុំពុំបានទៅសួរយោបល់ពីមនុស្សណាម្នាក់ ឡើយ។ [17]ខ្ញុំក៏ពុំបានឡើងទៅក្រុងយេរូសាឡឹម ដើម្បីជួបអស់លោកដែលជាគ្រីស្ដទូតមុនខ្ញុំដែរ គឺខ្ញុំបានធ្វើដំណើរទៅស្រុកអារ៉ាប៊ី រួចក៏ត្រឡប់មកក្រុងដាម៉ាសវិញ។

[18]បីឆ្នាំក្រោយមក ខ្ញុំបានឡើងទៅក្រុងយេរូសាឡឹម ដើម្បីឲ្យបានស្គាល់លោកកេផាសហើយខ្ញុំស្នាក់នៅជាមួយលោក អស់រយៈពេលដប់ប្រាំថ្ងៃ។ [19]ប៉ុន្តែខ្ញុំពុំបានជួបនឹងគ្រីស្ដទូត*ណាផ្សេងទៀតឡើយ លើកលែងតែលោកយ៉ាកុប ជាបងប្អូនរបស់ព្រះអម្ចាស់ប៉ុណ្ណោះ។ [20]សេចក្ដីដែលខ្ញុំសរសេរមកជូនបងប្អូននេះឥតកុហកទេ មានព្រះជាម្ចាស់ជាសាក្សីស្រាប់។

[21]បន្ទាប់មកទៀត ខ្ញុំបានធ្វើដំណើរទៅតំបន់ផ្សេងៗនៅស្រុកស៊ីរី និងស្រុកស៊ីលីស៊ី [22]តែព្រះសហគមន៍នានា ដែលជឿព្រះគ្រីស្ដនៅស្រុកយូដាពុំបានស្គាល់មុខខ្ញុំទេ។ [23]បងប្អូនទាំងនោះគ្រាន់តែបានឮគេនិយាយថា "អ្នកដែលបៀតបៀនយើងកាលពីដើម ឥឡូវនេះគាត់បែរជាផ្សព្វផ្សាយដំណឹងល្អ អំពីជំនឿដែលគាត់ចង់កម្ទេចពីមុននោះទៅវិញ!"។[24]គេក៏នាំគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រោះតែខ្ញុំ។

## ការប្រមូលផ្ដុំនៅក្រុងយេរូសាឡឹម

[2:1]ដប់បួនឆ្នាំក្រោយមក ខ្ញុំក៏បានឡើងទៅក្រុងយេរូសាឡឹមម្ដងទៀត ជាមួយលោកបារណាបាទាំងនាំលោកទីតូទៅជាមួយដែរ។ [2]ខ្ញុំឡើងទៅក្រុងយេរូសាឡឹមដូច្នេះ មកពីព្រះជាម្ចាស់បំភ្លឺចិត្តឲ្យដឹងថា ខ្ញុំត្រូវទៅ។ ខ្ញុំបានរៀបរាប់ប្រាប់បងប្អូនដែលនៅទីនោះអំពីដំណឹងល្អដែលខ្ញុំប្រកាសដល់សាសន៍ដទៃ ហើយខ្ញុំក៏បានរៀបរាប់ប្រាប់អស់លោក ជាអ្នកដឹកនាំដាច់ដោយឡែកពីគេដែរ ដើម្បីកុំឲ្យកិច្ចការដែលខ្ញុំកំពុងតែធ្វើ ឬបានធ្វើរួចមកហើយ ត្រឡប់ទៅជាអសារឥតការវិញ។ [3]រីឯលោកទីតូដែលទៅជាមួយខ្ញុំ ទោះបីគាត់ជាសាសន៍ក្រិកក្ដី ក៏គេពុំបានបង្ខំគាត់ឲ្យទទួលពិធីកាត់ស្បែក*ដែរ [4]ថ្វីដ្បិតតែមានពួកបងប្អូនក្លែងក្លាយជ្រៀតខ្លួនចូលមកក្នុងចំណោមយើង ដើម្បីឈ្លបមើលសេរីភាព ដែលយើងមានក្នុងអង្គព្រះគ្រីស្ដយេស៊ូ ក្នុងគោលបំណងធ្វើឲ្យយើងធ្លាក់ទៅជាទាសករវិញ។ [5]យើងពុំបានសុខចិត្តធ្វើតាមពួកគេឡើយ សូម្បីតែមួយភ្លែតក៏មិនធ្វើតាមផង ដើម្បីរក្សាការពារសេចក្ដីពិត នៃដំណឹងល្អសម្រាប់បងប្អូន។ [6]រីឯបងប្អូន ដែលគេគោរពទុកជាអ្នកដឹកនាំនោះវិញ(នៅពេលនោះគេមានឋានៈជាអ្វីក៏ដោយក៏ខ្ញុំមិនរវល់ដែរ ដ្បិតព្រះជាម្ចាស់មិនរើសមុខនរណាទេ) អ្នកដឹកនាំទាំងនោះពុំបានបង្ខំខ្ញុំ ឲ្យធ្វើអ្វីផ្សេងទៀតឡើយ។ [7]ផ្ទុយទៅវិញ គេបានឃើញថា ព្រះជាម្ចាស់ប្រគល់មុខងារផ្សព្វផ្សាយដំណឹងល្អ*ដល់សាសន៍ដទៃ មកឲ្យខ្ញុំដូចព្រះអង្គបានប្រគល់មុខងារផ្សព្វផ្សាយដំណឹងល្អដល់សាសន៍យូដាឲ្យបងសិលាដែរ [8]ដ្បិតព្រះជាម្ចាស់ដែលប្រោសប្រទានឲ្យបងសិលា អាចបំពេញមុខងារជាគ្រីស្ដទូត* សម្រាប់សាសន៍យូដាយ៉ាងណា ព្រះអង្គក៏ប្រោសប្រទានឲ្យខ្ញុំអាចបំពេញមុខងារជាគ្រីស្ដទូតសម្រាប់សាសន៍ដទៃ យ៉ាងនោះដែរ។ [9]

កាលលោកយ៉ាកុប លោកកេផាស និងលោកយ៉ូ
ហាន ដែលពួកបងប្អូនចាត់ទុកដូចជាបង្គោលរបស់
ព្រះសហគមន៍ បានទទួលស្គាល់ថា ព្រះជាម្ចាស់
ប្រោសប្រណី[គ]ដល់ខ្ញុំដូច្នេះ ក្រុមគាត់ក៏បានចាប់ដៃខ្ញុំ
និងចាប់ដៃលោកបារណាបាទុកជាសញ្ញាថា យើង
រួបរួមគ្នា គឺបងបារណាបានិងខ្ញុំទៅផ្សាយដំណឹងល្អ
ដល់សាសន៍ដទៃ រីឯក្រុមគាត់វិញទៅប្រកាសដំណឹង
ល្អដល់សាសន៍យូដា។ ១០អស់លោកគ្រាន់តែសុំឲ្យ
យើងគិតគូរដល់ជនក្រីក្រ[ឃ] ជាកិច្ចការដែលខ្ញុំខ្នះខ្នែង
បំពេញស្រាប់ហើយ។

## ការខ្វែងគំនិតគ្នាអន់ទីយ៉ូក

១១ក៏ប៉ុន្តែ នៅពេលដែលបងកេផាមកដល់ក្រុង
អន់ទីយ៉ូក ខ្ញុំក៏ជំទាស់នឹងលោកនៅមុខគេឯងទាំង
អស់គ្នា ព្រោះលោកបានធ្វើខុស។ ១២បងយ៉ាកុបបាន
ចាត់អ្នកខ្លះឲ្យមកក្រុងអន់ទីយ៉ូក។ មុនពេលអ្នកទាំង
នោះមកដល់ បងកេផាតែងបរិភោគរួមជាមួយបងប្អូន
សាសន៍ដទៃ តែពេលអ្នកទាំងនោះមកដល់គាត់បែរ
ជាដកខ្លួនថយចេញ ដាច់ឡែកពីបងប្អូនសាសន៍ដទៃ
ព្រោះគាត់ខ្លាចបងប្អូនសាសន៍យូដា[ង]។ ១៣បងប្អូន
សាសន៍យូដាឯទៀតៗ នាំគ្នាលាក់ពុតដូចគាត់ គឺសូ
ម្បីតែបងបារណាបាផ្ទាល់ ក៏ត្រូវគេអូសទាញឲ្យលាក់
ពុតដូចគេដែរ។ ១៤ពេលខ្ញុំឃើញបងប្អូនទាំងនោះ
លែងដើរត្រង់តាមសេចក្ដីពិតនៃដំណឹងល្អហើយនោះ
ខ្ញុំក៏ជម្រាបបងកេផានៅមុខគេឯងទាំងអស់គ្នាថា៖
"បើបងដែលជាសាសន៍យូដាលែងប្រព្រឹត្តតាម
របៀបសាសន៍យូដាទៀត តែបែរជាប្រព្រឹត្តតាម
របៀបសាសន៍ដទៃដូច្នេះ តើបងអាចបង្ខំសាសន៍ដទៃ
ឲ្យធ្វើដូចសាសន៍យូដាម្ដេចកើត?"។

១៥រីឯយើងវិញ យើងជាជាតិយូដាពីកំណើតមក
យើងមិនមែនជាអ្នកមានបាប ដូចសាសន៍ដទៃនោះ
ទេ។ ១៦យើងដឹងថា ព្រះជាម្ចាស់ពុំប្រោសមនុស្សឲ្យ
បានសុចរិត ដោយការប្រព្រឹត្តតាមធម្មវិន័យទេគឺបាន
សុចរិត ដោយសារជំនឿរបស់ព្រះយេស៊ូគ្រីស្ដវិញ។
ដូច្នេះ យើងផ្ញើជីវិតលើព្រះយេស៊ូគ្រីស្ដដែរ ដើម្បីព្រះ
ជាម្ចាស់ប្រោសយើងឲ្យបានសុចរិត មកពីជំនឿរបស់
ព្រះគ្រីស្ដ[ច] គឺមិនមែនដោយបានប្រព្រឹត្តតាមធម្មវិន័យ
នោះទេ ព្រោះគ្មាននរណាម្នាក់បានសុចរិតដោយ
ប្រព្រឹត្តតាមធម្មវិន័យឡើយ។ ១៧ប៉ុន្តែ ប្រសិនបើ
យើងប្រាថ្នាចង់បានសុចរិត ដោយរួមក្នុងព្រះគ្រីស្ដ
(តែក្រោយមក) បែរជាឃើញថាយើងនៅតែជាប់
បាបដូចគេនោះ បានសេចក្ដីថាព្រះគ្រីស្ដនាំឲ្យយើង
ជាប់បាប។ ទេ! មិនមែនដូច្នោះទេ! ១៨(ព្រោះថា)
ប្រសិនបើខ្ញុំបែរទៅពឹងលើធម្មវិន័យវិញ គឺធម្មវិន័យ
ដែលខ្ញុំបានបោះចោលហើយនោះ បានសេចក្ដីថាខ្ញុំ
ទទួលសារភាពថា ខ្ញុំប្រព្រឹត្តបំពាន[ឆ]លើធម្មវិន័យ។
១៩ ដោយសារធម្មវិន័យ ដែលបណ្ដាលឲ្យគេធ្វើគុត
ព្រះគ្រីស្ដ ខ្ញុំលែងរស់នៅទាំងខិតខំគោរពធម្មវិន័យ[ជ]
ទៀតហើយ តែខ្ញុំរស់នៅទាំងថ្វាយខ្លួនព្រះជាម្ចាស់វិ
ញ។ ខ្ញុំជាប់ឈើឆ្កាងរួមជាមួយព្រះគ្រីស្ដ ២០ដូច្នេះ
មិនមែនខ្ញុំទេដែលរស់ទៀតនោះ គឺព្រះគ្រីស្ដទេតើ
ដែលរស់នៅក្នុងរូបខ្ញុំ។ រីឯ ជីវិតខ្ញុំនៅពេលនេះ ខ្ញុំរស់
ដោយរួមជំនឿ ជាមួយព្រះបុត្រារបស់ព្រះជាម្ចាស់
ដែលបានស្រឡាញ់ខ្ញុំ និងបានបូជាព្រះជន្មសម្រាប់
ខ្ញុំ។ ២១ខ្ញុំមិនលុបបំបាត់ព្រះហឫទ័យប្រោសប្រណី
របស់ព្រះជាម្ចាស់ឡើយ។ ផ្ទុយទៅវិញប្រសិនបើព្រះ
ជាម្ចាស់ប្រោសឲ្យមនុស្សបានសុចរិតដោយសារធម្មវិ
ន័យនោះ បានសេចក្ដីថា ព្រះគ្រីស្ដសោយទិវង្គត
ដោយឥតបានការអ្វីសោះ!

## ជំនឿ និង ធម្មវិន័យ

១បងប្អូនកាឡាទីដ៏ល្ងីល្ងើអើយ! តើបងប្អូនត្រូវ
៣អំពើរបស់នរណា? បងប្អូនបានទទួលសេចក្ដី
បរិយាយ អំពីព្រះយេស៊ូគ្រីស្ដដែលត្រូវគេឆ្កាងនោះ
យ៉ាងច្បាស់លាស់ហើយទេតើ! ២ខ្ញុំគ្រាន់តែចង់ដឹង
សេចក្ដីមួយប៉ុណ្ណោះ សូមបងប្អូនប្រាប់ខ្ញុំមើល៍ តើបង
ប្អូនបានទទួលព្រះវិញ្ញាណ មកពីបងប្អូន បានប្រព្រឹត្ត

តាមធម្មវិន័យ ឬមកពីជឿដំណឹងល្អដែលបងប្អូនបានស្ដាប់? ៣ម្ដេចក៏បងប្អូនល្ងីល្ងើម្ល៉េះ! បងប្អូនចាប់ផ្ដើមជីវិតថ្មីដោយព្រះវិញ្ញាណ តែឥឡូវនេះម្ដេចក៏ចង់បញ្ចប់តាមរបៀបលោកីយ៍វិញដូច្នេះ? ៤បងប្អូនមានបទពិសោធន៍យ៉ាងច្រើននោះ តើអសារឥតការឬ? ទេ! មិនមែនឥតបានការឡើយ![ឈ] ៥ព្រះជាម្ចាស់បានប្រទានព្រះវិញ្ញាណមកបងប្អូន និងបញ្ចេញសកម្មភាពដោយសម្ដែងបាដិហារិយ៍ផ្សេងៗ ក្នុងចំណោមបងប្អូននោះ តើព្រះអង្គធ្វើដូច្នេះមកពីបងប្អូនប្រព្រឹត្តតាមធម្មវិន័យ ឬមកពីបងប្អូនបានជឿដំណឹងល្អ ដែលបងប្អូនបានស្ដាប់? ៦លោកអប្រាហាំជឿលើព្រះជាម្ចាស់ ហើយព្រះអង្គប្រោសឲ្យលោកបានសុចរិត ដោយយល់ដល់ជំនឿនេះ[ញ]។ ៧ដូច្នេះ សូមបងប្អូនយល់ថា អ្នកណាមានជំនឿ អ្នកនោះហើយជាកូនចៅរបស់លោកអប្រាហាំ។ ៨ក្នុងគម្ពីរមានគ្រោងទុកជាមុនថា ព្រះជាម្ចាស់នឹងប្រោសសាសន៍ដទៃឲ្យបានសុចរិត ដោយសារជំនឿ ហើយលោកអប្រាហាំបានទទួលដំណឹងល្អនេះ ជាមុនថា« ជាតិសាសន៍ទាំងអស់ នឹងទទួលពរដោយសារអ្នក»[ដ]។ ៩ហេតុនេះ អស់អ្នកដែលមានជំនឿក៏បានទទួលព្រះពរ រួមជាមួយលោកអប្រាហាំដែលមានជំនឿនោះដែរ។ ១០រីឯអស់អ្នកដែលពឹងផ្អែកលើកុសលផលបុណ្យតាមធម្មវិន័យនោះវិញ គេត្រូវបណ្ដាសាហើយ ដ្បិតមានចែងទុកមកថា *«អ្នកណាមិនប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មាន ដែលមានចែងទុកក្នុងគម្ពីរធម្មវិន័យយ៉ាងខ្ជាប់ខ្ជួនទេនោះ អ្នកនោះត្រូវបណ្ដាសាហើយ»*[ឋ]។ ១១មួយវិញទៀត យើងដឹងច្បាស់ថា គ្មាននរណាម្នាក់បានសុចរិតនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ ដោយសារធម្មវិន័យនោះឡើយ ដ្បិត *«មនុស្សសុចរិតដោយសារជំនឿ នឹងមានជីវិត»*[ឌ]។ ១២រីឯធម្មវិន័យប្លែកពីជំនឿទាំងស្រុង ព្រោះមានចែងថា *«អ្នកណាប្រតិបត្តិតាមសេចក្ដីទាំងអស់ចែងក្នុងធម្មវិន័យនឹងមានជីវិត ដោយបានប្រព្រឹត្តតាមសេចក្ដីទាំងនោះ»*[ឍ]។ ១៣ដោយព្រះគ្រីស្ដបានទទួលបណ្ដាសាសម្រាប់យើង ទ្រង់លោះយើងឲ្យរួចផុតពីបណ្ដាសាដែលមកពីធម្មវិន័យ ដ្បិតមានចែងទុកមកថា *«អ្នកណាដែលត្រូវគេព្យួរជាប់នឹងឈើអ្នកនោះត្រូវបណ្ដាសាហើយ!»*[ណ]។ ១៤ហេតុការណ៍នេះកើតដូច្នេះ ដើម្បីឲ្យព្រះពរដែលលោកអប្រាហាំទទួលបានហូរទៅដល់សាសន៍ដទៃ ដោយសារព្រះគ្រីស្ដយេស៊ូដែរ ហើយឲ្យយើងទទួលព្រះវិញ្ញាណដែលព្រះជាម្ចាស់បានសន្យាថា នឹងប្រទានមកដោយយើងមានជំនឿ។

## ធម្មវិន័យ និង ព្រះបន្ទូលសន្យា

១៥ខ្ញុំសូមលើកយកឧទាហរណ៍មួយ មកជម្រាបបងប្អូនថា ប្រសិនបើពាក្យបណ្ដាំរបស់មនុស្សចែងទុកត្រឹមត្រូវហើយ គ្មាននរណាម្នាក់លុបបំបាត់ ឬបន្ថែមបន្ថយអ្វីបានទេ។ ១៦យ៉ាងណាមិញ ព្រះជាម្ចាស់មានព្រះបន្ទូលសន្យាដល់លោកអប្រាហាំ និងដល់ពូជពង្សរបស់លោក។ ក្នុងគម្ពីរពុំមានចែងថា«*ដល់ពូជពង្សទាំងឡាយ*» ហាក់ដូចជា សំដៅទៅលើពូជពង្សដ៏ច្រើនឡើយ គឺសំដៅទៅលើពូជពង្សតែម្នាក់ប៉ុណ្ណោះ៖ *«ដល់ពូជពង្សរបស់អ្នក»* ពោលគឺដល់ព្រះគ្រីស្ដ។ ១៧ខ្ញុំនិយាយដូច្នេះ ចង់ពន្យល់ថា ព្រះជាម្ចាស់បានទុកពាក្យបណ្ដាំមួយយ៉ាងត្រឹមត្រូវរួចស្រេចហើយ។ រីឯវិន័យដែលមកដល់បួនរយសាមសិបឆ្នាំក្រោយមកទៀតនោះ ពុំបានលុបបំបាត់ពាក្យបណ្ដាំរបស់ព្រះអង្គឡើយ បើពុំនោះទេព្រះបន្ទូលសន្យាមុខជាបាត់ខ្លឹមសារមិនខាន។ ១៨ប្រសិនបើព្រះជាម្ចាស់ប្រទានមត៌កមកមនុស្ស ព្រោះគេប្រព្រឹត្តតាមធម្មវិន័យ បានសេចក្ដីថា គេមិនទទួលមត៌កនោះតាមព្រះបន្ទូលសន្យាទៀតឡើយ។ ក៏ប៉ុន្តែ ព្រះជាម្ចាស់ប្រោសប្រណីលោកអប្រាហាំ ដោយសារព្រះបន្ទូលសន្យារបស់ព្រះអង្គ។

១៩បើដូច្នោះតើធម្មវិន័យមានប្រយោជន៍អ្វី? ធម្មវិ

ន័យមកតាមក្រោយ ដើម្បីបង្ហាញបទល្មើសរបស់
មនុស្ស ហើយមានខ្លឹមសាររហូតទាល់តែពូជពង្ស[ត]
ដែលត្រូវទទួលមត៌កតាមព្រះបន្ទូលសន្យា យាងមក
ដល់។ ពួកទេវទូត*បាននាំយកធម្មវិន័យនេះមក
តាមរយៈមនុស្សម្នាក់ដែលធ្វើអន្តរាគមន៍[ថ]។ ២០ប៉ុន្តែ
ប្រសិនបើមានតែម្នាក់នោះ មិនបាច់ឲ្យមាននរណាធ្វើ
អន្តរាគមន៍ឡើយ។ រីឯព្រះជាម្ចាស់វិញ មានតែមួយ
ព្រះអង្គប៉ុណ្ណោះ។

២១ដូច្នេះតើបានសេចក្ដីថា ធម្មវិន័យទាស់នឹង
ព្រះបន្ទូលសន្យាឬ? ទេ! មិនមែនដូច្នោះទេ! ប្រសិន
បើធម្មវិន័យដែលមនុស្សបានទទួល អាចផ្ដល់ជីវិត
បានសេចក្ដីថា មនុស្សនឹងបានសុចរិតដោយសារធម្ម
វិន័យមែន ២២ក៏ប៉ុន្តែ ក្នុងគម្ពីរមានចែងថា អ្វីៗទាំង
អស់សុទ្ធតែនៅក្រោមអំណាចបាប ដើម្បីឲ្យអស់អ្នក
ជឿបានទទួលផល ស្របតាមព្រះបន្ទូលសន្យា
ដោយសារជំនឿរបស់ព្រះយេស៊ូគ្រីស្ត។

២៣មុនពេលជំនឿមកដល់ យើងជាប់ឃុំឃាំង
ក្រោមអំណាចរបស់ធម្មវិន័យ ទាំងរង់ចាំជំនឿដែល
នឹងត្រូវលេចចេញមក។ ២៤ដូច្នេះវិន័យមាននាទី
ណែនាំយើងទៅកាន់ព្រះគ្រីស្ត ដើម្បីឲ្យយើងបាន
សុចរិតដោយសារជំនឿ។ ២៥កាលណាជំនឿមកដល់
ហើយ យើងមិនស្ថិតនៅក្រោមធម្មវិន័យដែលណែនាំ
យើងនោះទៀតទេ ២៦ដ្បិតដោយសារជំនឿលើព្រះ
គ្រីស្តយេស៊ូ បងប្អូនសុទ្ធតែជាបុត្រធីតារបស់ព្រះជា
ម្ចាស់។ ២៧បងប្អូនទាំងអស់គ្នាបានទទួលពិធីជ្រមុជ
ទឹក* ដើម្បីឲ្យបានរួមជាមួយព្រះគ្រីស្តបងប្អូនក៏មាន
ព្រះគ្រីស្តនៅជាប់ជាមួយដែរ[ទ]។

២៨ដូច្នេះគ្មានសាសន៍យូដា គ្មានសាសន៍ក្រិក
ទៀតទេ ហើយក៏គ្មានទាសករ គ្មានអ្នកជា គ្មានបុរស
គ្មានស្ត្រីទៀតដែរ គឺបងប្អូនទាំងអស់បានរួមគ្នាមកជា
អង្គតែមួយ ក្នុងព្រះគ្រីស្តយេស៊ូ។ ២៩ប្រសិនបើបង
ប្អូនចូលរួមជាមួយព្រះគ្រីស្ត បងប្អូនជាពូជពង្សរបស់
លោកអប្រាហាំ ហើយក៏ត្រូវទទួលមត៌កតាមព្រះ
បន្ទូលសន្យាដែរ។

១ខ្ញុំសូមជម្រាបថា ដរាបណាកូនដែលត្រូវទទួលម
ត៌កនៅក្មេងនៅឡើយ គេមិនខុសពីទាសករទេ ថ្វី
ដ្បិតតែគេជាម្ចាស់លើទ្រព្យសម្បត្តិទាំងអស់ក៏ដោយ
២កូននោះនៅក្រោមការគ្រប់គ្រងរបស់អ្នកអាណា
ព្យាបាល និងអ្នកមើលខុសត្រូវលើទ្រព្យសម្បត្តិ
រហូតដល់ពេលដែលឪពុកបានកំណត់ទុក។ ៣រីឯ
យើងវិញក៏ដូច្នោះដែរ កាលនៅក្មេងខ្ចី[ធ]នៅឡើយ
យើងធ្វើជាទាសករនៃអ្វីៗជាអរូប ដែលមានឥទ្ធិពល
លើលោកីយ៍[ន]នេះ ៤ប៉ុន្តែលុះដល់ពេលកំណត់ហើយ
ព្រះជាម្ចាស់ក៏ចាត់ព្រះបុត្រារបស់ព្រះអង្គ ឲ្យមក
ប្រសូតចេញពីស្ត្រី ហើយប្រសូតក្រោមអំណាចរបស់
ធម្មវិន័យផង ៥ដើម្បីលោះអស់អ្នកដែលស្ថិតនៅ
ក្រោមអំណាចធម្មវិន័យ និងឲ្យយើងទទួលឋានៈជា
បុត្រធីតា[ប]របស់ព្រះអង្គ។ ៦បងប្អូនពិតជាបុត្រធីតា
របស់ព្រះជាម្ចាស់មែន ព្រោះព្រះអង្គបានចាត់ព្រះ
វិញ្ញាណនៃព្រះបុត្រារបស់ព្រះអង្គ ឲ្យមកសណ្ឋិតក្នុង
ចិត្តយើង គឺព្រះវិញ្ញាណនេះហើយដែលបន្លឺព្រះសូរ
សៀងឡើងថា *«អប្បា[ផ]! ឱព្រះបិតា!»*។ ៧ដូច្នេះ
អ្នកមិនមែនជាទាសករទៀតទេ គឺអ្នកជាបុត្រធីតា
របស់ព្រះអង្គវិញ។ បើអ្នកជាបុត្រធីតាមែន អ្នកក៏ត្រូវ
ទទួលមត៌កដែលព្រះជាម្ចាស់ប្រទានឲ្យនោះដែរ។

## គ្រីស្តទូតប៉ូលព្រួយបារម្ភ

៨កាលពីដើម បងប្អូនពុំស្គាល់ព្រះជាម្ចាស់ទេ
ហើយក៏ធ្វើជាទាសកររបស់ព្រះនានា ដែលមិនមែន
ជាព្រះពិតប្រាកដ។ ៩តែឥឡូវនេះ បងប្អូនស្គាល់ព្រះ
ជាម្ចាស់ បើនិយាយឲ្យចំ ព្រះអង្គបានស្គាល់បងប្អូន
វិញ ហេតុដូចម្ដេចបានជា បងប្អូនបែរជាវិលទៅចុះ
ចូលនឹងធាតុដ៏អរូបី ដែលមានឥទ្ធិពលលើលោកីយ៍
ហើយចង់ទៅជាទាសករនៃធាតុដ៏ទន់ខ្សោយគ្មាន
បារមីទាំងនោះ សាជាថ្មីវិញដូច្នេះ? ១០បើបងប្អូន

គោរពថ្ងៃខែ គោរពរដូវ និងគោរពឆ្នាំ។ ១១ខ្ញុំបារម្ភ
ក្រែងតែការនឿយហត់ដែលខ្ញុំធ្វើសម្រាប់បងប្អូនត្រ
ឡប់ទៅជាឥតបានផលអ្វីសោះ។

១២ខ្ញុំអង្វរបងប្អូនថា សូមកាន់ចិត្តឲ្យបានដូចខ្ញុំ
ព្រោះខ្ញុំបានកាន់ចិត្តដូចបងប្អូនដែរ។ បងប្អូនពុំបាន
ធ្វើអ្វីខុសចំពោះរូបខ្ញុំទេ។ ១៣បងប្អូនជ្រាបស្រាប់
ហើយថា ខ្ញុំបាននាំដំណឹងល្អមកជូនបងប្អូនជាលើក
ទីមួយ មកពីខ្ញុំមានជំងឺ។ ១៤ក៏ប៉ុន្តែ ទោះបីជំងឺរបស់ខ្ញុំ
បណ្ដាលឲ្យបងប្អូនលំបាកយ៉ាងណាក៏ដោយ ក៏បង
ប្អូនពុំបានមើលងាយ ឬស្អប់ខ្ពើមខ្ញុំដែរ ផ្ទុយទៅវិញ
បងប្អូនបានទទួលខ្ញុំ ទុកដូចទទួលទេវទូត*របស់ព្រះ
ជាម្ចាស់ ឬដូចទទួលព្រះគ្រិស្តយេស៊ូដែរ។ ១៥តើ
អំណរសប្បាយដែលបងប្អូនធ្លាប់មានកាលពីមុននោះ
នៅឯណា? ដ្បិតខ្ញុំហ៊ានធ្វើជាសាក្សីថា នៅពេល
នោះ សូម្បីតែភ្នែករបស់បងប្អូនក៏បងប្អូនសុខចិត្តខ្វេះ
ឲ្យខ្ញុំដែរ ប្រសិនបើបងប្អូនអាចធ្វើបាន។ ១៦ឥឡូវនេះ
តើបងប្អូនចាត់ទុកខ្ញុំជាសត្រូវ មកពីខ្ញុំនិយាយសេចក្ដី
ពិតឬ?

១៧រីឯពួកគេវិញ គេយកចិត្តទុកដាក់នឹងបងប្អូន
ណាស់ តែក្នុងគោលបំណងមិនល្អទេ គេចង់បំបែក
បងប្អូនចេញពីយើង ដើម្បីឲ្យបងប្អូនយកចិត្តទុកដាក់
ចំពោះគេវិញតែប៉ុណ្ណោះ។ ១៨ការយកចិត្តទុកដាក់
ដោយមានគោលបំណងល្អគ្រប់ពេលវេលានោះ ត្រឹម
ត្រូវហើយ គឺមិនគ្រាន់តែនៅពេលដែលខ្ញុំនៅជាមួយ
ប៉ុណ្ណោះទេ។ ១៩កូនចៅអើយ! ខ្ញុំឈឺចាប់ក្នុងការ
បង្កើតកូនចៅសាជាថ្មី ប្រៀបបីដូចស្ត្រីឈឺចាប់នៅ
ពេលហៀបនឹងឆ្លងទន្លេយ៉ាងនោះដែរគឺរហូតទាល់តែ
ព្រះគ្រិស្តបានកើតជារូបរាងឡើងក្នុងបងប្អូន។ ២០ខ្ញុំ
ចង់នៅជិតបងប្អូនឥឡូវនេះណាស់ដើម្បីនិយាយ
ជាមួយបងប្អូនផ្ទាល់ តាមរបៀបមួយផ្សេងទៀត ដ្បិត
ខ្ញុំទ័លគំនិត មិនដឹងជាត្រូវសរសេរយ៉ាងដូចម្ដេចមក
បងប្អូនទេ។

## សម្ពន្ធមេត្រីចាស់ និង សម្ពន្ធមេត្រីថ្មី

២១បងប្អូន ដែលជាអ្នកចង់ចុះចូលនឹងធម្មវិន័យ
អើយ! សូមប្រាប់ខ្ញុំមើល៍ តើបងប្អូនមិនយល់សេចក្ដី
ដែលមានចែងទុកក្នុងវិន័យមកទេឬ? ២២ក្នុងគម្ពីរ
មានចែងទុកមកថា លោកអប្រាហាំមានកូនប្រុសពីរ
នាក់ គឺម្នាក់ជាកូនរបស់ស្ត្រីជាទាសករ ម្នាក់ទៀតជា
កូនរបស់ស្ត្រីអ្នកជា[ព]។ ២៣ក៏ប៉ុន្តែកូនរបស់ស្ត្រីទាស
ករនោះ កើតមកតាមរបៀបលោកីយ៍ រីឯកូនរបស់ស្ត្រី
អ្នកជាវិញ កើតមកតាមព្រះបន្ទូលសន្យារបស់ព្រះជា
ម្ចាស់។ ២៤យើងអាចចាត់ទុករឿងនេះជានិមិត្តរូបមួយ
ដែរ ដ្បិតស្ត្រីទាំងពីរនេះជាតំណាងសម្ព័ន្ធមេត្រី*ពីរ
ម្នាក់ជាតំណាងនៃសម្ព័ន្ធមេត្រី ដែលចងនៅភ្នំស៊ីណៃ
[ភ] ពោលគឺនាងហាការដែលបង្កើតកូនជាទាសករ។
២៥នាងហាការជាតំណាងភ្នំស៊ីណៃ នៅស្រុកអារ៉ាប៊ី
ជានិមិត្តរូបនៃក្រុងយេរូសាឡឹមសព្វថ្ងៃនេះ[ម] ដ្បិតនាង
ហាការនិងកូនចៅរបស់នាងសុទ្ធតែជាទាសករ។ ២៦
រីឯ ក្រុងយេរូសាឡឹមនៅស្ថានលើវិញ[យ] គឺស្ត្រីអ្នកជា
ដែលជាមាតារបស់យើងហ្នឹងហើយ ២៧ដ្បិតមានចែង
ទុកមកថា៖ «នាងជាស្ត្រីអារ នាងជាស្ត្រីមិនបាន
បង្កើតកូនអើយ! ចូរអរសប្បាយឡើង! នាងដែលពុំ
ធ្លាប់ឈឺផ្ទៃអើយ! ចូរបន្លឺសំឡេងស្រែកដោយអំណរ
ឡើង! ដ្បិតកូនរបស់ស្ត្រីដែលប្ដីបោះបង់ចោលនោះ
មានចំនួនច្រើនជាងកូនរបស់ស្ត្រី ដែលមានប្ដីទៅទៀ
ត។»[រ]

២៨បងប្អូនជាបុត្រធីតា តាមព្រះបន្ទូលសន្យាដូច
លោកអ៊ីសាកដែរ។ ២៩ប៉ុន្តែពីអតីតកាល កូនដែល
កើតមកតាមរបៀបលោកីយ៍ ធ្វើទុក្ខបៀតបៀនកូន
ដែលកើតមកតាមព្រះវិញ្ញាណយ៉ាងណា នៅបច្ចុប្បន្ន
កាលក៏នឹងមានយ៉ាងនោះដែរ។ ៣០តើក្នុងគម្ពីរមាន
ចែងទុកដូចម្ដេច? គឺមានចែងថា៖*«ចូរបណ្ដេញស្ត្រី
អ្នកបម្រើ និងកូនរបស់នាងចេញទៅ ដ្បិតកូនរបស់
ស្ត្រីអ្នកជាពុំត្រូវទទួលមត៌ករួម ជាមួយកូនរបស់ស្ត្រី*

*ទាសករឡើយ»*[ល]។ ៣១ហេតុនេះ យើងមិនមែនជា
កូនរបស់ស្ត្រីទាសករទេ គឺជាកូនរបស់ស្ត្រីអ្នកជា។

## សេរីភាពរបស់គ្រីស្តបរិស័ទ

១ព្រះគ្រីស្តបានរំដោះយើង ឲ្យមានសេរីភាពពិត
ៗប្រាកដ ហេតុនេះចូររក្សាសេរីភាពនេះឲ្យបាន
ខ្ជាប់ខ្ជួន កុំបណ្តោយខ្លួនធ្លាក់ទៅជាទាសករទៀតឡើ
យ។

២រីឯខ្ញុំប៉ូល ខ្ញុំសូមជម្រាបបងប្អូនថា ប្រសិនបើ
បងប្អូនទទួលពិធីកាត់ស្បែក*នោះ ព្រះគ្រីស្តលែង
មានប្រយោជន៍អ្វីដល់បងប្អូនទៀតហើយ។ ៣ចំពោះ
អស់អ្នកដែលចង់ទទួលពិធីកាត់ស្បែក ខ្ញុំសូមបញ្ជាក់
ប្រាប់ម្តងទៀតថា ត្រូវតែកាន់តាមធម្មវិន័យទាំងស្រុង
ផងទៅ។ ៤ប្រសិនបើបងប្អូនណាចង់បានសុចរិត
ដោយកាន់ធម្មវិន័យ បងប្អូននោះបែកចេញពីព្រះគ្រី
ស្ត ហើយក៏ដាច់ចេញពីព្រះហឫទ័យប្រោសប្រណី
របស់ព្រះជាម្ចាស់ដែរ។ ៥រីឯយើងវិញ ដោយយើង
មានជំនឿ ព្រះវិញ្ញាណនឹងជួយយើងឲ្យទន្ទឹងរង់ចាំ
ព្រះជាម្ចាស់ប្រោសឲ្យយើងបានសុចរិត ស្របតាម
សេចក្តីសង្ឃឹមរបស់យើងជាមិនខាន។ ៦ចំពោះអ្នក
ដែលរួមរស់ជាមួយព្រះគ្រីស្តយេស៊ូ ការកាត់ស្បែកឬ
មិនកាត់ស្បែកនោះ មិនសំខាន់អ្វីឡើយគឺមានតែ
ជំនឿដែលនាំឲ្យប្រព្រឹត្តអំពើផ្សេងៗ ដោយចិត្ត
ស្រឡាញ់ប៉ុណ្ណោះទើបសំខាន់។

៧បងប្អូនបានចាប់ផ្តើមជឿល្អណាស់' តើនរណា
រារាំងបងប្អូន មិនឲ្យស្តាប់បង្គាប់សេចក្តីពិតដូច្នេះ?
៨ការបញ្ចុះបញ្ចូលបែបនេះមិនមែនមានប្រភព មកពី
ព្រះជាម្ចាស់ដែលបានត្រាស់ហៅបងប្អូនទេ។ ៩*«មេ
ម្សៅតែបន្តិច អាចធ្វើឲ្យម្សៅទាំងមូលដោរឡើង
បាន»*[ស]។ ១០ចំពោះខ្ញុំ ព្រះអម្ចាស់ធ្វើឲ្យខ្ញុំទុកចិត្តបង
ប្អូនថា បងប្អូនមុខជាមិនបែកគំនិតទៅរកអ្វីផ្សេង
សោះឡើយ។ រីឯអ្នកដែលធ្វើឲ្យបងប្អូនកើតវឹកវរ
នោះវិញ ទោះជានរណាក៏ដោយ គេត្រូវតែទទួល
ទោសពុំខាន។ ១១បងប្អូន! ចំពោះខ្ញុំវិញ ប្រសិនបើខ្ញុំ
ប្រកាសឲ្យធ្វើពិធីកាត់ស្បែកទៀតនោះ ម្តេចក៏គេនៅ
តែបៀតបៀនខ្ញុំទៀត? ប្រសិនបើខ្ញុំប្រកាសដូច្នេះ
ដំណឹងល្អអំពីព្រះគ្រីស្តត្រូវគេឆ្កាង នឹងលែងធ្វើឲ្យគេ
រវាតចិត្តឃ្លាតចាកពីជំនឿទៀតហើយ។ ១២អ្នកដែល
នាំឲ្យបងប្អូនជ្រួលច្របល់បែបនេះ ត្រូវតែក្រៀវខ្លួន
ឯងតែម្តងទៅ។

## ជីវិតខាងព្រះវិញ្ញាណ

១៣ព្រះជាម្ចាស់បានត្រាស់ហៅបងប្អូន ឲ្យមាន
សេរីភាព ក៏ប៉ុន្តែសូមកុំយកសេរីភាពនេះមកធ្វើជា
លេស ដើម្បីរស់តាមរបៀបលោកីយ៍សោះឡើយផ្ទុយ
ទៅវិញ ត្រូវបម្រើគ្នាទៅវិញទៅមកដោយចិត្ត
ស្រឡាញ់ ១៤ដ្បិតធម្មវិន័យទាំងមូលសរុបមកត្រឹមតែ
ឃ្លាមួយនេះថា *«អ្នកត្រូវស្រឡាញ់បងប្អូនឯទៀតៗ
ឲ្យបានដូចស្រឡាញ់ខ្លួនឯងដែរ»*[ហ]។ ១៥បើបងប្អូន
ប្រខាំគ្នា និងហែកហួរគ្នាទៅវិញទៅមកដូច្នេះ ចូរ
ប្រយ័ត្នក្រែងលោបងប្អូនត្រូវវិនាសអន្តរាយ ដោយ
សារតែគ្នាឯង។

១៦ខ្ញុំសូមជម្រាបថា ចូររស់នៅឲ្យស្របតាមព្រះ
វិញ្ញាណ នោះបងប្អូននឹងមិនបំពេញតាមបំណង
តណ្ហារបស់លោកីយ៍ទៀតឡើយ ១៧ដ្បិតចំណង់
តណ្ហាលោកីយ៍ តែងតែទាស់នឹងព្រះវិញ្ញាណ ហើយ
ព្រះវិញ្ញាណក៏ទាស់នឹងលោកីយ៍ដែរ។ លោកីយ៍និង
ព្រះវិញ្ញាណផ្ទុយគ្នាទាំងស្រុង ដូច្នេះបងប្អូនពុំអាចធ្វើ
អ្វីដែលបងប្អូនចង់ធ្វើនោះបានឡើយ។ ១៨ប្រសិនបើ
ព្រះវិញ្ញាណណែនាំបងប្អូន បងប្អូនលែងនៅក្រោម
អំណាចរបស់ធម្មវិន័យទៀតហើយ។

១៩យើងស្គាល់ច្បាស់នូវអំពើផ្សេងៗ ដែលកើត
ចេញមកពីលោកីយ៍ គឺមានអំពើប្រាសចាកសីលធម៌
អំពើសៅហ្មងកាមគុណថោកទាប ២០ការថ្វាយបង្គំ
ព្រះក្លែងក្លាយ វិជ្ជាធ្មប់ ឈ្លោះប្រកែកគ្នា បាក់បែកគ្នា
ច្រណែនគ្នា កំហឹងឃោរឃៅ ប្រកួតប្រជែងគ្នា

ប្រឆាំងគ្នា ប្រកាន់បក្សពួក ²¹ឈ្នានីសគ្នា ប្រមឹកស៊ីផឹកជ្រុល និងអំពើផ្សេងៗទៀតដែលស្រដៀងនឹងអំពើទាំងនេះដែរ។ ខ្ញុំសូមជម្រាបឲ្យបងប្អូនដឹងជាមុន ដូចខ្ញុំបាននិយាយរួចមកហើយថា អស់អ្នកដែលប្រព្រឹត្តអំពើទាំងអស់នេះ ពុំអាចទទួលព្រះរាជ្យ* របស់ព្រះជាម្ចាស់ទុកជាមត៌កបានឡើយ។

²²រីឯផលដែលកើតមកពីព្រះវិញ្ញាណវិញ គឺសេចក្ដីស្រឡាញ់ អំណរ សេចក្ដីសុខសាន្ត ចិត្តអត់ធ្មត់ ចិត្តសប្បុរស ចិត្តសន្ដោសមេត្តា ជំនឿ ²³ចិត្តស្លូតបូត ចេះទប់ចិត្តខ្លួនឯង។ គ្មានធម្មវិន័យណាជំទាស់នឹងសេចក្ដីទាំងនេះទេ។

²⁴អស់អ្នកដែលរួមជាមួយព្រះគ្រីស្ដយេស៊ូ សុទ្ធតែបានឆ្កាងតណ្ហា និងបំណងរបស់លោកីយ៍នោះចោលហើយ។ ²⁵ប្រសិនបើយើងមានជីវិតដោយសារព្រះវិញ្ញាណមែន យើងក៏ត្រូវប្រតិបត្តិតាមព្រះវិញ្ញាណដែរ។

²⁶យើងមិនត្រូវអួតបំប៉ោង រករឿងគ្នាទៅវិញទៅមក និង ឈ្នានីសគ្នានោះឡើយ។

## ការជួយធុរៈគ្នាទៅវិញទៅមក

¹បងប្អូន! ប្រសិនបើមាននរណាម្នាក់ត្រូវគេទាន់
៦នៅពេលកំពុងតែធ្វើអំពើអាក្រក់ណាមួយ បងប្អូនដែលមានព្រះវិញ្ញាណនៅក្នុងខ្លួន ត្រូវកែតម្រង់អ្នកនោះដោយចិត្តស្លូតបូត។ ក៏ប៉ុន្តែតោងប្រយ័ត្នខ្លួនក្រែងលោអ្នកត្រូវធ្លាក់ក្នុងការល្បួងដូចគេដែរ។ ²ត្រូវ
ជួយរំលែកទុក្ខធុរៈគ្នាទៅវិញទៅមក ធ្វើយ៉ាងនេះទើបបងប្អូនបំពេញតាមធម្មវិន័យរបស់ព្រះគ្រីស្ដ* ទាំងស្រុង។ ³ប្រសិនបើនរណាម្នាក់ស្មានថា ខ្លួនជា
មនុស្សសំខាន់ តែតាមពិតខ្លួនជាអ្នកឥតបានការ អ្នកនោះបញ្ឆោតខ្លួនឯងហើយ។ ⁴ម្នាក់ៗត្រូវពិនិត្យ
ពិច័យមើលអំពើដែលខ្លួនប្រព្រឹត្ត ប្រសិនបើរកឃើញហេតុដែលធ្វើឲ្យខ្លួនឯងខ្ពស់មុខនោះ គឺរកឃើញតែ
នៅក្នុងខ្លួនឯងផ្ទាល់ មិនមែនដោយប្រៀបផ្ទឹមទៅនឹងអ្នកដទៃទេ ⁵ដ្បិតម្នាក់ៗទទួលខុសត្រូវលើអំពើដែល
ខ្លួនប្រព្រឹត្ត។

⁶ចំពោះអ្នកដែលទទួលការអប់រំ ខាងព្រះបន្ទូល ត្រូវយកអ្វីៗទាំងប៉ុន្មាន ដែលខ្លួនមានមួយចំណែក មកចែកដល់អ្នកដែលអប់រំខ្លួននោះផង។

⁷សូមបងប្អូនកុំយល់ច្រឡំ គ្មាននរណាមើលងាយព្រះជាម្ចាស់បានទេ។ បើមនុស្សម្នាក់សាបព្រោះគ្រាប់ពូជណា គេនឹងច្រូតបានផលតាមពូជនោះឯង។ ⁸អ្នកណាសាបព្រោះខាងលោកីយ៍ អ្នក
នោះក៏នឹងច្រូតយកផលមកពីលោកីយ៍ គឺផលដែលត្រូវរលួយដែរ។ រីឯអ្នកដែលសាបព្រោះខាងព្រះវិញ្ញាណវិញ នឹងច្រូតយកផលមកពីព្រះវិញ្ញាណ គឺជាជីវិតអស់កល្បជានិច្ច។ ⁹យើងមិនត្រូវនឿយណាយ
នឹងប្រព្រឹត្តអំពើល្អឡើយ ដ្បិតប្រសិនបើយើងមិនបាក់ទឹកចិត្តទេនោះ ដល់ពេលកំណត់យើងនឹងច្រូតបានផលជាមិនខាន។ ¹⁰ហេតុនេះ ពេលយើងមាន
ឱកាសនៅឡើយ យើងត្រូវប្រព្រឹត្តអំពើល្អចំពោះមនុស្សទាំងអស់ ជាពិសេសចំពោះបងប្អូនរួមជំនឿ។

## ពាក្យដាស់តឿនចុងបញ្ចប់

¹¹តួអក្សរធំៗដែលបងប្អូនឃើញនេះ គឺខ្ញុំបានសរសេរមកបងប្អូនដោយដៃខ្ញុំផ្ទាល់។

¹²អស់អ្នកដែលចង់បានកិត្តិយស ខាងលោកីយ៍ បានបង្ខំបងប្អូនឲ្យកាត់ស្បែក* ក្នុងគោលបំណងកុំឲ្យមានគេបៀតបៀន ព្រោះតែឈើឆ្កាងរបស់ព្រះគ្រីស្ដប៉ុណ្ណោះ។ ¹³ចំពោះអ្នកដែលកាត់ស្បែកទាំងនោះ
ខ្លួនគេផ្ទាល់ពុំកាន់តាមវិន័យទេគឺគេចង់ឲ្យបងប្អូនកាត់ស្បែក ដើម្បីឲ្យគេអាចអួតខ្លួនថា គេបានកាត់ស្បែកឲ្យបងប្អូន។ ¹⁴រីឯខ្ញុំវិញ ខ្ញុំមិនអួតខ្លួនអំពីអ្វី
ក្រៅពីឈើឆ្កាងរបស់ព្រះយេស៊ូគ្រីស្ដជាព្រះអម្ចាស់នៃយើងឡើយ។ ដោយសារឈើឆ្កាងនេះ អ្វីៗក្នុងពិភពលោកដូចជាជាប់ឈើឆ្កាងដែរ លែងមានទាក់

ទាមនឹងខ្ញុំទៀតហើយ ហើយខ្ញុំក៏ជាប់ឈើឆ្កាងលែង
មានទាក់ទាមអ្វីនឹងពិភពលោកទៀតដែរ[ឡ]។ ១៥ពិធី
កាត់ស្បែកឬមិនកាត់ស្បែកមិនសំខាន់អ្វីទេ មានតែ
កើតជាថ្មីវិញឯណោះទើបសំខាន់។ ១៦សូមព្រះជា
ម្ចាស់ប្រទានសេចក្តីសុខសាន្ត និងមេត្តាករុណាដល់
អស់អ្នក ដែលអនុវត្តតាមគោលគំនិតនេះ និងដល់
ប្រជារាស្ត្រអ៊ីស្រាអែលរបស់ព្រះអង្គ។

១៧អំណើះតទៅ សូមកុំឲ្យនរណាម្នាក់ធ្វើឲ្យខ្ញុំ
ពិបាកចិត្តទៀតឡើយ ដ្បិតខ្ញុំមានស្លាកស្នាម[អ]របស់
ព្រះយេស៊ូ នៅក្នុងរូបកាយខ្ញុំស្រាប់ហើយ។

១៨បងប្អូន! សូមព្រះយេស៊ូគ្រីស្ត*ជាព្រះអម្ចាស់
នៃយើងប្រោសប្រណីដល់វិញ្ញាណរបស់បងប្អូន។អា
ម៉ែន។

ក.ពាក្យដើម«ពីសាច់ពីឈាម»ចង់សំដៅទៅលើនិស្ស័យរបស់មនុស្សលោកឬមនុស្សលោកផ្ទាល់។•ខ. យើងអាចបកស្រាយពាក្យ«ទាសករ»ត្រង់នេះថាជាទាសករឬខ្ញុំបម្រើរបស់ធម្មវិន័យគឺមានន័យថាត្រូវតែប្រព្រឹត្តតាមវិន័យរបស់លោកម៉ូសេគ្រប់ប្រការទាំងអស់។

គ. ព្រះជាម្ចាស់ប្រោសប្រណីលោកប៉ូលត្រង់នេះយើងអាចបកស្រាយថាព្រះអង្គប្រគល់មុខងារឲ្យលោកធ្វើជាគ្រីស្តទូតសម្រាប់សាសន៍ដទៃ។•ឃ. ជនក្រីក្រត្រង់នេះចង់សំដៅទៅលើគ្រីស្តបរិស័ទក្រីក្រនៅក្រុងយេរូសាឡឹម។•ង.ពាក្យដើម«សាសន៍កាត់ស្បែក»។តាមវិន័យរបស់សាសន៍យូដាអ្នកកាត់ស្បែកមិនអាចបរិភោគជាមួយអ្នកដែលមិនកាត់ស្បែកបានទេព្រោះគេចាត់ទុកថាជាមនុស្សមិនបរិសុទ្ធ។គ្រីស្តបរិស័ទជាជាតិយូដានៅសម័យនោះនៅតែជំពាក់ចិត្តនឹងវិន័យរបស់លោកម៉ូសេនេះដដែល។•ច. ជំនឿរបស់ព្រះគ្រីស្តគឺជំនឿដែលមកពីព្រះគ្រីស្តមានន័យថាយើងរួមជាមួយព្រះគ្រីស្តក្នុងជំនឿរបស់ព្រះអង្គចំពោះព្រះបិតា។

ឆ.ឃ្លានេះមានន័យថា:ដោយសារជំនឿលើព្រះគ្រីស្តខ្ញុំមិនពឹងផ្អែកលើវិន័យទៀតទេប៉ុន្តែបើខ្ញុំវិលទៅពឹងផ្អែកលើការប្រព្រឹត្តតាមវិន័យម្តងទៀតនោះបានសេចក្តីថាខ្ញុំបានយល់ថាខ្ញុំប្រព្រឹត្តបំពានលើវិន័យនោះហើយ។•ជ.ឃ្លាដើមសរសេរថា«ដោយសារវិន័យខ្ញុំបានស្លាប់ខាងវិន័យ»។ពាក្យ«ដោយសារវិន័យប៉»មានន័យថាព្រះគ្រីស្តបានសោយទិវង្គតស្របតាមវិន័យហើយធ្វើឲ្យមនុស្សរួចផុតពីទោសដែលកើតមកពីការបំពានលើវិន័យ។•ឈ. យើងអាចបកប្រែឃ្លានេះតាមរបៀបផ្សេងទៀតថា«បើឥតបានការគ្រាន់បើជាង!»។•ញ. កំណើតពិភពលោក(លោកុប្បត្តិ)១៥.៦។•ដ. កំណើតពិភពលោក១២.៣។

ឋ.ទុតិយកថា២៧.២៦។•ឱ.ហាបាគូក២.៤។•ឍ.លេវីវិន័យ១៨.៥។•ណ.ទុតិយកថា២១.២៣។•ត.«ពូជពង្ស»នេះ ចង់សំដៅទៅលើព្រះយេស៊ូ។•ថ. ព្រះជាម្ចាស់ប្រទានគម្ពីរវិន័យមកតាមរយៈលោកម៉ូសេ។

ទ. ឃ្លាដើម«បងប្អូនក៏បានបំពាក់ព្រះគ្រីស្តពីលើបងប្អូនដែរ»។•ធ.មានន័យថាកាលយើងមិនទាន់ជឿព្រះយេស៊ូនៅឡើយ។•ន. «អ្វីៗដែលមានឥទ្ធិពលក្នុងលោកីយ៍នេះ»ចង់សំដៅទៅលើយមយក្សអារុក្ខអារក្សអ្នកតាព្រៃភ្នំនិងខ្មោចព្រាយបិសាចជាដើម។•ប.ពាក្យដើមកូនចិញ្ចឹម។•ផ. សូមអានសេចក្តីពន្យល់នៅរ៉ូម៨.១៥។

ព. កូនប្រុសទាំងពីររបស់លោកអប្រាហាំគឺអ៊ីស្មាអែល(ម្តាយរបស់អ៊ីស្មាអែលគឺនាងហាការជាស្ត្រីបម្រើ)និងអ៊ីសាក(ម្តាយរបស់អ៊ីសាកគឺនាងសារ៉ាជាភរិយាពេញច្បាប់)-កំណើតពិភពលោក(លោកុប្បត្តិ)១៦.១៥;២១-២។•ភ. ព្រះជាម្ចាស់ចងសម្ពន្ធមេត្រីជាមួយសាសន៍អ៊ីស្រាអែលនៅលើភ្នំស៊ីណៃ។•ម.ក្រុងយេរូសាឡឹមសព្វថ្ងៃចង់សំដៅទៅលើសាសន៍យូដាដែលមិនព្រមជឿថាព្រះយេស៊ូជាព្រះគ្រីស្តហើយគេនៅជាប់ជាខ្ញុំបម្រើរបស់វិន័យនៅឡើយ។

យ. «ក្រុងយេរូសាឡឹមនៅស្ថានលើ»គឺស្ថានបរមសុខ។•រ. អេសាយ៥៤.១។•ល.កំណើតពិភពលោក២១.១០។•វ.ឃ្លាដើម«បងប្អូនបានរត់ទៅមុខល្អណាស់»។•ស.ពាក្យស្លោកដែលដាស់តឿនឲ្យប្រុងប្រយ័ត្ន(សូមអាន១កូរិនថូស៥.៦)។

ហ. លេវីវិន័យ ១៩.១៨។

ឡ.ឃ្លាដើម:«ដោយសារឈើឆ្កាងនេះលោកីយ៍ក៏ដូចជាបានជាប់
ឆ្កាងសម្រាប់ខ្ញុំហើយខ្ញុំក៏បានជាប់ឆ្កាងសម្រាប់លោកីយ៍ដែរ»។•អ
. នៅសម័យដើមពួកខ្ញុំបម្រើតែងតែមានស្លាកស្នាមពីលើខ្លួនដើម្បី
បញ្ជាក់ថាគេជាកម្មសិទ្ធិរបស់ម្ចាស់ណាមួយ។លោកប៉ូលត្រូវគេវាយ
ធ្វើបាបហើយមានស្លាកស្នាមលើខ្លួនមកពីលោកបម្រើព្រះគ្រីស្ទ។

ឈ. អេសាយ ២២.១៣។ • ញ. កំណើតពិភពលោក ២.៧។ • ដ.
លោកប៉ូលប្រើនាមនេះសំដៅទៅលើព្រះយេស៊ូគ្រីស្ទ។